ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ORIGINAL

# គំរោងអភិវឌ្ឍន៍វារីអគ្គិសនីកំចាយ

## DEVELOPMENT OF KAMCHAY HYDROELECTRIC PROJECT

# ការវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង

# Initial Environmental and Social Impact Assessment (IESIA)



Draft

របស់ក្រុមហ៊ុន

**SINOHYDRO CORPORATION**

ទីស្នាក់ការក្រុមហ៊ុន: ផ្ទះលេខ ២៣ ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ

បរៀងដោយ: SAWAC

epared by: CONSULTANTS FOR DEVELOPMENT

តុលា ២០០៦

EW
160

Draft

EW 160

ORIGINAL

# ជំពូក ១

## លក្ខណៈទូទៅ

## General

Draft

This item belongs to the
Open Development Cambodia Library

# ជំពូកទី ១

## លក្ខណៈទូទៅ (General)

### ១.១ សេចក្តីផ្តើម

ក្នុងបរិយាកាសនៃស្ថានភាពបច្ចុប្បន្ននេះ មុខសញ្ញាវិនិយោគគ្រប់ប្រភេទសុទ្ធតែមានសារៈសំខាន់សំរាប់ កម្ពុជាទាំងអស់ ទាំងការវិនិយោគផលិតទំនិញនាំចេញ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ការស្វែងរកប្រភពទាក់ទាញទេសចរណ៍ និង ការផលិតថាមពលអគ្គិសនីដោយប្រើចរន្តទឹក គឺវារីអគ្គិសនីដែលជា សក្តានុពលដ៏សំខាន់នៃការរីកចំរើនសេដ្ឋកិច្ចរបស់កម្ពុជា ។

ពិតមែនតែគ្រប់វិស័យសុទ្ធតែមានសារៈសំខាន់ដូចៗគ្នា សំរាប់បំរើការអភិវឌ្ឍន៍ ប៉ុន្តែវារីអគ្គិសនីជាវិស័យអាទិភាពមួយ ដែលមានលក្ខណៈសមស្របនិងចាំបាច់ចំពោះស្ថាភាពបច្ចុប្បន្នប្រេងឥន្ធនៈឡើងថ្លៃ ហើយមិនបំពុលខ្យល់ (ដោយ $CO_2$, $NO_2$, $SO_2$...etc) ទៀតផង ។ ដោយហេតុថាប្រទេសកម្ពុជាស្ថិតក្នុងតំបន់ត្រូពិចដែលមានភ្លៀងធ្លាក់រយៈពេលប្រាំមួយខែក្នុងមួយឆ្នាំ រួមផ្សំនឹងសណ្ឋានដីសំបូរដោយជួរភ្នំនិងជ្រលងភ្នំនៅតាមបន្ទាត់ព្រំដែន និងតំបន់ឆ្នេរ បង្កអោយមានសក្តានុពលសំរាប់អភិវឌ្ឍន៍វារីអគ្គិសនី ជាពិសេស គឺតំបន់កំចាយ ខេត្តកំពតនេះតែម្តង។ ក្នុងគោលដៅស្រូបយកផលប្រយោជន៍ដ៏សំបូរបែប ដែលជាអំណោយផលធម្មជាតិរបស់កម្ពុជា និងក្នុងគោលដៅចូលរួម ចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា កាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ចលើគ្រប់វិស័យស្របតាម គោលនយោបាយរបស់រាជរដ្ឋាភិបាល នោះសម៉ីក្រសួង (ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ) និងក្រុមហ៊ុន SINOHYDRO បានប្រមើលឃើញថាការវិនិយោគវិស័យវារីអគ្គិសនី គឺជាមុខសញ្ញាវិនិយោគសមស្រប និងសំខាន់បំផុតក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន។

ផ្តើមចេញពីការសិក្សាយ៉ាងល្អិតល្អន់ព្រមទាំងមានបទពិសោធន៍ជាច្រើនរួចមក ហើយនៅប្រទេសចិន ក្រុមហ៊ុនបានសំរេចថានឹងវិនិយោគលើវិស័យវារីអគ្គិសនីនៅប្រទេសកម្ពុជា។ នៅក្នុងការដេញថ្លៃប្រកួតប្រជែងជាចំហ និងលក្ខណៈអន្តរជាតិយកសិទ្ធិធ្វើការវិនិយោគ ដែលបានធ្វើឡើងពីខែមិថុនា ២០០៤ ដល់ ខែមករា ២០០៥ ក្រុមហ៊ុន SINOHYDRO Corporation Limited នៃសាធារណរដ្ឋប្រជាមានិតចិន បានឈ្នះលេខមួយ ហើយនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះកិច្ចសន្យាស្តីពីការវិនិយោគទុនប្រភេទ " BOT " លើគំរោងអភិវឌ្ឍន៍វារីអគ្គិសនីកំចាយខេត្តកំពត ជាមួយនឹងក្រុមហ៊ុន SINOHYDRO Corporation Limited. ដែលមានរយៈពេល ៤៤ ឆ្នាំ រាប់ទាំងរយៈពេលសាងសង់ ៤ឆ្នាំផង។

ដោយមានការព្រមព្រៀងរវាងក្រុមហ៊ុន SINOHYDRO Corporation Limited. ជាមួយ និង SAWAC, Consultants for Development (ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍) ដើម្បីរៀបចំរបាយកាណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) លើគំរោងវារីអគ្គិសនីកំចាយខេត្តកំពត របស់ក្រុមហ៊ុន SINOHYDRO Corporation Limited។ SAWAC បានចាត់ក្រុមជំនាញផ្នែកបរិស្ថាន ចុះទៅធ្វើការសិក្សាផ្ទាល់នៅ ក្នុងតំបន់គំរោងដែលមានទំហំដូចតទៅ តំបន់ខាងលើទំនប់ (RCC

This item belongs to the Open Development Cambodia Library

Dam) ប្រមាណ ៣៨០៦,៤៦ ហិតា តំបន់ខាងក្រោម ទំនប់អមតាមដងស្ទឹងទឹកឈូ រហូតដល់ព្រំប្រទល់ស្រុកកំពត ចាប់តាំងពីថ្ងៃទី ០៣ ដល់ ១៦/០៩/២០០៦ ហើយធ្វើការវិភាគ និង រៀបរៀបចំរបាយការណ៍សំរេច ក្នុងរយៈជាងពីរខែ (ថ្ងៃទី ១៦ សីហា ដល់ ២៣ តុលា ២០០៦) ។

នៅក្នុងឯកសារនេះបានបង្ហាញអំពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូងរបស់គំរោង វិនិយោគទុនលើវិស័យវារីអគ្គិសនីកំចាយនៅខេត្តកំពត របស់ក្រុមហ៊ុន SINOHYDRO Corporation Limited ។ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូងនេះមាន ៨ ជំពូក (១) លក្ខណៈទូទៅ, (២) ក្របខ័ណ្ឌច្បាប់ ដែលពាក់ព័ន្ធ, (៣) ការពិពណ៌នាអំពីគំរោង , (៤) ស្ថានភាពបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង, (៥) ហេតុប៉ះពាល់ បរិស្ថានសំខាន់ៗ និងវិធានការកាត់បន្ថយនៅក្នុងតំបន់គំរោង , (៦) ការប្រឹក្សា និង ពិគ្រោះយោបល់ពីសាធារណជនក្នុងតំបន់គំរោង , (៧) ផែនការគ្រប់គ្រងបរិស្ថាននៅក្នុងតំបន់គំរោង , និង (៨) សន្និដ្ឋាន និងសំណូមពរ ។

## ១.២ គោលបំណងនៃការសិក្សា និង វាយតំលៃ

ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នោះរាល់គំរោងអភិវឌ្ឍន៍ទាំងអស់ ត្រូវធ្វើការសិក្សាវាយតំលៃលើហេតុប៉ះពាល់បរិស្ថានជាមុនសិន រួចនឹងឈានចូលការអនុវត្តន៍គំរោង និងយោងតាមច្បាប់កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និង អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ការសិក្សាសំរាប់កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់គំរោងនេះ គឺមានគោលបំណងសំខាន់ៗដូចតទៅ :

- ស្វែងយល់ដឹងពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់ ។
- ពិនិត្យជាលើកដំបូងនៃតំបន់គំរោងនឹងអភិវឌ្ឍន៍ និង សិក្សាតំបន់ជុំវិញគំរោងដែលអាចទទួលរងនូវឥទ្ធិពលដោយផ្ទាល់ ឬ ដោយប្រយោលពីគំរោងស្នើសុំអភិវឌ្ឍន៍នេះ ។
- វាយតំលៃ និងប៉ាន់ប្រមាណហេតុប៉ះពាល់លើធនធានបរិស្ថានធម្មជាតិ និង សង្គមដែលបណ្តាលមកពីការគ្រោងរចនា ការសាងសង់ និងប្រតិបត្តិគំរោង ។
- កំណត់នូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថានវិជ្ជមាន និងអវិជ្ជមានដែលកើតឡើងពីសកម្មភាពរបស់គំរោងដោយប្រើប្រាស់ តារាង Checklist របស់ធានាគារអភិវឌ្ឍអាស៊ី និងរបស់ក្រសួងបរិស្ថានកម្ពុជា ។
- កំណត់នូវវិធានការណ៍កាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ជាពិសេសលើបរិស្ថានសង្គមឱ្យដល់កំរិតអប្បបរមា
- ដកស្រង់នូវអនុសាសន៍ និងទទួលយកនូវសំណូមពររបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង និងស្ថាប័នសាធារណៈដែលពាក់ព័ន្ធ នឹងគំរោងក្នុងនោះក៏មានអង្គការក្រៅរដ្ឋាភិបាលផងដែរ ។
- កំណត់នូវផែនការការពារបរិស្ថានរបស់គំរោងទៅថ្ងៃអនាគត ។

## ១.៣ វិធីសាស្ត្រនៃការសិក្សា

ចំណុចសំខាន់ៗនៃវិធីសាស្ត្រក្នុងការសិក្សាលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមដំបូង (IESIA) របស់គំរោងវិនិយោគទុនលើវិស័យវារីអគ្គិសនីស្ថិតនៅស្រុកកំពត ខេត្តកំពត របស់ក្រុមហ៊ុន SINOHYDRO Corporation Limited. មានដូចតទៅ :

- ប្រមូលទិន្នន័យ និងពត៌មានដែលទាក់ទងជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់នៅភ្នំពេញដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងផែនការ ឧទ្យានជាតិបូកគោ សាម៉ីក្រុមហ៊ុន និងស្ថាប័នទាក់ទង មួយចំនួនទៀត។
- ការចុះប្រមូលទិន្នន័យដល់ទីតាំងភូមិសាស្ត្ររបស់គំរោង និងមានការប្រឹក្សាពិគ្រោះយោបល់ពីសាធារណជន . មេភូមិ . មេឃុំ . អភិបាលស្រុក និងស្ថាប័នពាក់ព័ន្ធដូចជា មន្ទីឧស្សាហកម្ម. មន្ទីទេសចរណ៍. មន្ទីរកសិកម្មខេត្តកំពត. មន្ទីរបរិស្ថានខេត្តកំពត. មន្ទីរធនធានទឹកខេត្តកំពត និង អង្គការមិនមែនរដ្ឋាភិបាល (NGOs) មួយចំនួន ។ (សូមពិនិត្យមើលជំពូក ៦ កំណត់ហេតុ)
- ការចុះអង្កេតសិក្សាពីបរិស្ថានធម្មជាតិដោយផ្ទាល់លើទីតាំងគំរោងដូចជាការសិក្សា ប្រព័ន្ធជលសាស្ត្រ ដី ព្រៃឈើ សត្វព្រៃ មច្ឆជាតិ ។ល។ ដោយ មានការបង្ហាញពីអ្នកភូមិផ្ទាល់ (លទ្ធផលការរាប់ព្រៃមានចែងក្នុងតារាងលេខ ៦ ដល់លេខ ៨) ។
- ការចុះអង្កេតសិក្សារកដីដែលប្រើប្រាស់ (ដីប៉ះពាល់) របស់ប្រជាពលរដ្ឋក្នុងតំបន់ទីតាំងគំរោង (សូមពិនិត្យមើលផែនទីលេខ៣)
- ការចុះសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលមានដីប៉ះពាល់ក្នុងតំបន់អភិវឌ្ឍន៍គំរោង ។
- ការយកគំរូសាក និងធ្វើការវិភាគលើគុណភាពទឹកផ្ទាល់នៅប្រភពធនធានទឹកពីរកន្លែងនៃស្ទឹងទឹកឈូ (ទាំងខាងលើ និងខាងក្រោមតំបន់ទំនប់អាងស្តុកទឹកក្នុងតំបន់គំរោង) ដោយប្រើឧបករណ៍តេស្តទឹក HACH2000, Digital pH, Temperature និង Mettler Toledo DO-meter (សូមពិនិត្យមើលតារាងតេស្តទឹកនៅទីកន្លែងផ្ទាល់របស់គំរោងក្នុងឧបសម្ព័ន្ធ២) ដើម្បីរកករឹតគុណភាពប្រភពទឹកដើមមុនការអភិវឌ្ឍន៍គំរោង ។ ការធ្វើតេស្តទឹករកប៉ារ៉ាម៉ែត្រមួយចំនួនទៀតដូចជា BOD, COD, Total Coliform, SS, Total Nitrogen, and Total Phosphorus គំរូសាកត្រូវបានបញ្ជូនមកធ្វើការវិភាគនៅមន្ទីរ ពិសោធន៍គុណភាពទឹករបស់ក្រសួងបរិស្ថាន ។
- ធ្វើការវិភាគទិន្នន័យទាំងអស់ដែលប្រមូលបាន និង រៀបរាប់អំពីស្ថានភាពបរិស្ថានធម្មជាតិ និងសង្គមដែលមានស្រាប់ រួចធ្វើការប៉ាន់ប្រមាណពីស្ថានភាពបរិស្ថានទាំងនោះដែលអាចកើតមានឡើងនៅក្នុងកំឡុងពេលរចនាប្លង់ សាងសង់ ប្រតិបត្តិ និង ថែទាំ និងបញ្ចប់គំរោង។
- ពិនិត្យ និង សំរួលឡើងវិញនូវផែនការមេរបស់គំរោង ។
- កំណត់ទំហំឥទ្ធិពលហេតុប៉ះពាល់អវិជ្ជមាន និងវិជ្ជមានដែលបណ្តាលមកពីសកម្មភាពរបស់គំរោង ។ រិះរកវិធានការណ៍កាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានឱ្យដល់កំរិតអប្បបរមា ហើយធ្វើឱ្យប្រសើរឡើងនូវហេតុប៉ះពាល់បរិស្ថានវិជ្ជមានឱ្យដល់កំរិតអតិបរមា ដោយដកស្រង់ពីការប្រឹក្សាជាសាធារណៈ និងសំណូមពរផ្សេងៗពីប្រជាពលរដ្ឋ និងស្ថាប័នដែលពាក់ព័ន្ធ ក្នុងតំបន់គំរោង។
- រៀបចំផែនការគ្រប់គ្រងបរិស្ថាន Environmental Management Plan (EMP) ដោយមានដាក់ កម្មវិធីត្រួតពិនិត្យ (Monitoring Program) នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិ ថែទាំគំរោងទៀតផង ។

## គំនូសបំព្រួញនៃវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវអំពី IESIA របស់គំរោង




Draft